# សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

## របាយការណ៍វឌ្ឍនភាពការងារ
## ប្រចាំឆ្នាំ ២០១៧
## និង ផែនការសម្រាប់ឆ្នាំ២០១៨

រៀបចំដោយ: លោក ហ៊ុយ វណ្ណា

អគ្គលេខាធិការ

# មាតិកា


១. សេចក្ដីផ្ដើម ........ 1

២. អំពីសមាគម ........ 1

៣.សកម្មភាព និងលទ្ធផលការងារ ........ 3

៤.កិច្ចប្រជុំនានារបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ........ 6

៥.របាយការណ៍អភិវឌ្ឍន៍វិស័យសំណង់ ........ 22

៦.របាយការណ៍ហិរញ្ញវត្ថុឆ្នាំ ២០១៧ ........ 22

៧.ផែនការហិរញ្ញវត្ថុឆ្នាំ ២០១៨ ........ 22

៨.ផែនការអនុវត្តបន្ត ........ 23

# សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា
# របាយការណ៍វឌ្ឍនភាពការងារប្រចាំឆ្នាំ ២០១៧
# និង ផែនការសម្រាប់ឆ្នាំ២០១៨

## ១. សេចក្តីផ្តើម

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានរៀបចំ "**របាយការណ៍ស្តីពីវឌ្ឍនភាពការងារ ប្រចាំឆ្នាំ២០១៧ និង ផែនការសម្រាប់ឆ្នាំ ២០១៨**" ក្នុងគោលបំណងដើម្បីបង្ហាញពីសកម្មភាព និងលទ្ធផលការងារដែលសមាគមសម្រេច បានជូនថ្នាក់ដឹកនាំ និងសមាជិក-សមាជិកា ជ្រាបជារបាយការណ៍។ ស្របតាមសកម្មភាព និងលទ្ធផលការងារដែល សមាគមបានសម្រេចក្នុងឆ្នាំ២០១៧ យ៉ាងសកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់ សមាគមនូវតែបន្តរៀបចំចក្ខុវិស័យ ច្បាស់លាស់ ជាបេសកកម្មសម្រាប់អនុវត្តនៅឆ្នាំ២០១៨ បន្ថែមទៀត។

## ២. អំពីសមាគម

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានបន្តអនុវត្តការងារយ៉ាង សកម្មស្របតាមទស្សនវិស័យរួមរបស់សមាគម និងសេចក្តីត្រូវការរបស់សមាជិក-សមាជិកា។ ការបន្តគាំទ្រ និងការ លើកទឹកចិត្ត របស់សមាជិក-សមាជិកាសមាគម បានជម្រុញឲ្យសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា កាន់តែរឹងមាំ និងរីកចម្រើនមួយកម្រិតទៀត។ ការកើនឡើងសមាជិកសមាគមចំនួន ១០ ក្រុមហ៊ុនបន្ថែមទៀត បានឆ្លុះបញ្ចាំងពី កាលានុវត្តភាព និងសក្តានុពលរបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជានូវតែល្អប្រសើរ។

- **សមាជិកភាព**

| ល.រ | បេក្ខភាព | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | សរុប |
|---|---|---|---|---|
| ១ | ប្រធានកិត្តិយស | ១ | | ១ |
| ២ | ប្រធាន | ១ | | ១ |
| ៣ | អនុប្រធាន | ៩ | | ៩ |
| ៤ | សមាជិក | ២១ | +១០ | ៣១ |
| **សរុប** | | **៣២** | **+១០** | **៤២** |

❖ **បញ្ជីរាយនាមថ្នាក់ដឹកនាំ សមាជិក-សមាជិក សមាគមមាន ៤២រូបៈ**

| ល.រ | ឈ្មោះ | តួនាទី | សម្គាល់ |
|---|---|---|---|
| ១ | អ្នកឧកញ៉ា ហុង ពីវ | ប្រធានកិត្តិយស | ក្រុមហ៊ុន បុរី ពិភពថ្មី |
| ២ | ឧកញ៉ា លី ហួរ | ប្រធាន | ក្រុមហ៊ុន បុរី វិមានភ្នំពេញ |
| ៣ | ឧកញ៉ា ថៃ ជាហួត | អនុប្រធាន | ក្រុមហ៊ុន បុរី ប៉េង ហួត គ្រុប |
| ៤ | ឧកញ៉ា លាង ម៉េង | អនុប្រធាន | ក្រុមហ៊ុន បុរី ជីប ម៉ុងលែន |
| ៥ | ឧកញ៉ា ជាម យុនណាត | អនុប្រធាន | ក្រុមហ៊ុន បុរី មេគង្គរ៉ូយ៉ាល់ |
| ៦ | ឧកញ៉ា តេង ហឿង | អនុប្រធាន | ក្រុមហ៊ុន បុរី អគីដេវរីឡា |
| ៧ | ជំទាវ ខា ឡេង | អនុប្រធាន | ក្រុមហ៊ុន Alpha Property Construction |
| ៨ | ជំទាវឧកញ៉ា កែវ ម៉ាលី | អនុប្រធាន | ក្រុមហ៊ុន ខុនដូ វិមានចរណៃ |
| ៩ | ឧកញ៉ា លី សេងឃាង | អនុប្រធាន | ក្រុមហ៊ុន បុរី ចតុមុខ |
| ១០ | ឧកញ៉ា លាង សាំង | អនុប្រធាន | ក្រុមហ៊ុន បុរី ហាយធិច |
| ១១ | ឧកញ៉ា តាំង គួង | អនុប្រធាន | ក្រុមហ៊ុន តាំង គួង គ្រុប |
| ១២ | ឧកញ៉ា ប៊ុន ហៃ | សមាជិក | ក្រុមហ៊ុន បុរី ភ្នំពេញថ្មី |
| ១៣ | ឧកញ៉ា ថៃ ឈុនគ្រី | សមាជិក | ក្រុមហ៊ុន បុរី ថៃ ឈុនគ្រី |
| ១៤ | ឧកញ៉ា ព្រំ សុធី | សមាជិក | ក្រុមហ៊ុន បុរី អង្គរភ្នំពេញ |
| ១៥ | ឧកញ៉ា លីម ឈាងហាក់ | សមាជិក | ក្រុមហ៊ុន បុរី លីម ឈាងហាក់ |
| ១៦ | លោក ចាន់ សុង | សមាជិក | ក្រុមហ៊ុន Sino Plazza |
| ១៧ | លោក ទន់ ឆៃលីម | សមាជិក | ក្រុមហ៊ុន បុរី តាំង លីម |
| ១៨ | លោក ខួយ អ៊ាងឡាយ | សមាជិក | ក្រុមហ៊ុន បុរី ហុងឡាយ |
| ១៩ | លោក អ៊ីវ ម៉េង | សមាជិក | ក្រុមហ៊ុន សំណង់ល្អ ថ្មីពេញចិត្ត |
| ២០ | ឯកឧត្តម មាស វណ្ណា | សមាជិក | ក្រុមហ៊ុន បុរី ញ៉ូវ ថោន |
| ២១ | ឧកញ៉ា គង់ ប៊ុនហាវ | សមាជិក | ក្រុមហ៊ុន បុរី វីឡាទួលសង្កែ |
| ២២ | ឯកឧត្តម តុល លន | សមាជិក | ក្រុមហ៊ុន បុរី ធូ លន |
| ២៣ | លោក ព្រំ ខយ | សមាជិក | ក្រុមហ៊ុន ផ្ទះល្វែង សូឈីវ ព្រំខយ |
| ២៤ | លោក ស្រេង ឈាងហោ | សមាជិក | ក្រុមហ៊ុន បុរី លឹម ឈាងហោ |
| ២៥ | លោក កែ ចាន់ | សមាជិក | ក្រុមហ៊ុន សំណង់លំនៅដ្ឋាន សម្បត្តិមាស |
| ២៦ | លោក ជា រី | សមាជិក | ក្រុមហ៊ុន បុរី ជារី |
| ២៧ | ជំទាវ សែម សមួស្ស | សមាជិក | ក្រុមហ៊ុន បុរី សម្បត្តិ មានហេង ៣ |
| ២៨ | លោក អាន វ៉ាឌី | សមាជិក | ក្រុមហ៊ុន បុរី មង្គលភ្នំពេញ |
| ២៩ | ជំទាវ សេង វារី | សមាជិក | ក្រុមហ៊ុន បុរី វ៉ារីណា |
| ៣០ | លោក យៀត ផេង | សមាជិក | ក្រុមហ៊ុន បុរី ហាយលែន ស៊ីធីខនស្ត្រាក់សិន |
| ៣១ | លោក សួ សុខចេង | សមាជិក | ក្រុមហ៊ុន បុរី រិទ្ធិ |

| | | | |
|---|---|---|---|
| ៣២ | លោក ឡៅ តុងហាំង | សមាជិក | ក្រុមហ៊ុន បុរី PS Crystal |
| ៣៣ | លោក ម៉េង ងួន | សមាជិក | ក្រុមហ៊ុន Campaint |
| ៣៤ | ឧកញ៉ា សៀ រិទ្ធី | សមាជិក | ក្រុមហ៊ុន Oxley World bridge |
| ៣៥ | ឧកញ៉ា ស៊ី ហ៊ូហ៊ុយ | សមាជិក | ក្រុមហ៊ុន ស៊ី ហ៊ូហ៊ុយ គ្រុប |
| ៣៦ | ឧកញ៉ា លី គួង | សមាជិក | ក្រុមហ៊ុន Big House Commercial Corporation |
| ៣៧ | លោក គួច លេងឃាង | សមាជិក | ក្រុមហ៊ុន P.H One Development |
| ៣៨ | លោក ជូ កែវសម្បត្តិ | សមាជិក | ក្រុមហ៊ុន Yuan Chuang Real Estate |
| ៣៩ | ឧកញ៉ា ហេង វុទ្ធី | សមាជិក | T&B Import Export and Construction Co.,Ltd |
| ៤០ | លោក ឈី ឡាយ | សមាជិក | EKCO CONCRETE CO.,LTD |
| ៤១ | Mr. WU CHEN | សមាជិក | JUL Property Development Co.,Ltd |
| ៤២ | លោក សៅ ភក្តី | សមាជិក | អាណាចក្រ ឌីវេឡុបមេន គ្រុប ឯ.ក |

❖ **បញ្ជីរាយនាមអគ្គលេខាធិការដ្ឋានសមាគម មាន *៩រូប*៖**

| ល.រ | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | ឯកឧត្តម ហ៊ុន ម៉ានី | ទីប្រឹក្សាជាន់ខ្ពស់ |
| ២ | ឯកឧត្តម ហ៊ុយ វណ្ណៈ | ទីប្រឹក្សា |
| ៣ | ជំទាវឧកញ៉ា ចាន់ សុទ្ធា | ទីប្រឹក្សា |
| ៤ | បណ្ឌិត តាន់ មុនីវណ្ណ | ទីប្រឹក្សា |
| ៥ | លោក ហ៊ុយ វណ្ណា | អគ្គលេខាធិការ |
| ៦ | លោក អ៊ូច ពិសាល | ជំនួយការប្រធាន |
| ៧ | លោក ប៊ិ វណ្ណៈ | មេធាវី |
| ៨ | លោក គឹម ធារិទ្ធ | ហេរញ្ញិក |
| ៩ | កញ្ញា ប៉ូ សុគន្ធា | រដ្ឋបាល និងលេខា |

## ៣.សកម្មភាព និងលទ្ធផលការងារ

ក្រោមការដឹកនាំរបស់ **លោកឧកញ៉ា លី ហួរ** ជាប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានធ្វើការដឹកនាំ និងបម្រើការងារជូនសមាជិក-សមាជិកាសមាគម ប្រកបដោយសមិទ្ធផលជាច្រើន ដែលសមាគមសម្រេចបានដូចតទៅ៖

❖ **ការបង្កើតការិយាល័យសមាគមថ្មី**

អគ្គលេខាធិការដ្ឋាន បានរៀបចំឱ្យមានការិយាល័យថ្មីមួយមានទំហំធំជាងមុន សម្រាប់បុគ្គលិកបម្រើការងារ និងទំនាក់ទំនងការងារជាមួយសមាជិក-សមាជិកាឲ្យកាន់តែជិតស្និទ្ធ។ ការរៀបចំការិយាល័យថ្មីនេះ ស្របពេលសមាគមមានសក្តានុពលបង្កើនសមាជិកបន្ថែមទៀត ដែលការិយាល័យនេះមានអាសយដ្ឋានស្ថិតនៅអគារក្រុមហ៊ុន

លី ហួរ គ្រុប (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី) ជាន់ទី៥ អាគារលេខ ៨៥-៨៨ មហាវិថី គីមអ៊ីលស៊ុង សង្កាត់ បឹងកក់២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ។




រូបភាព៖ បន្ទប់ប្រជុំ




រូបភាព៖ ផ្ទាំងថតរូប



រូបភាព៖ បន្ទប់ទទួលភ្ញៀវ



រូបភាព៖ សកម្មភាពបុគ្គលិកបំពេញការងារ

## ❖ ការរៀបចំធ្វើកន្លាស់អាវ អំពីមាស

អគ្គលេខាធិការដ្ឋាន បានរៀបចំធ្វើកន្លាស់អាវអំពីមាស ក្នុងគោលបំណងផ្តល់ជូនថ្នាក់ដឹកនាំ និងសមាជិក-សមាជិការបស់សមាគមជាវត្ថុអនុស្សាវរីយ៍ និងលើកទឹកចិត្ត ក្នុងបុព្វហេតុដ៏សំខាន់ក្នុងការលះបង់ធនធានផ្សេងៗ ក្នុងការបង្កើតសមាគមនេះឡើង និងចូលរួមគាំទ្រសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានឲ្យមានសកម្មភាពរហូតមកដល់បច្ចុប្បន្ននេះ។

រូបភាព៖ គំរូកន្លាស់អាវ អំពីមាស



### ❖ ការធ្វើអណ្តូងទឹកចំនួន ៥ នៅខេត្តពោធិ៍សាត់

នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ ក្រោមការស្នើសុំយោបល់របស់លោក ហ៊ុយ វណ្ណា អគ្គលេខាធិការសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា និងមានការឯកភាពពី លោកឧកញ៉ា លី ហួរ ប្រធានសមាគម បានសម្រេចផ្តល់អណ្តូងស្នប់ ចំនួន ៥អណ្តូង ស្មើនឹងទឹកប្រាក់សរុបជិត ១ម៉ឺនដុល្លារអាមេរិក ដល់ប្រជាពលរដ្ឋដែលស្ថិតនៅតំបន់ដាច់ស្រយាល សម្រាប់ប្រើប្រាស់ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់។ អណ្តូងទាំងនោះបានផ្តល់ឲ្យសម្រាប់ឃុំក្រពើ ស្រុកវាលវែង មាន ៥ភូមិ ៖ ភូមិក្រពើពីលើ ១ អណ្តូង, ភូមិសំឡាញ ១ អណ្តូង, ភូមិក្រសាំងឆ្មៅ ១ អណ្តូង ភូមិកុំប៉ង ១ អណ្តូង និងភូមិអូរចេក ១ អណ្តូង។



រូបភាព៖ លោកហ៊ុយ វណ្ណា អគ្គលេខាធិការសមាគមចុះត្រួតពិនិត្យការសាងសង់អណ្តូងដោយផ្ទាល់



រូបភាព៖ អណ្តូងសាងសង់រួច

### ❖ ការដោះស្រាយបញ្ហាស្នើសុំបង់ពន្ធលើវិស័យសំណង់ជាគម្រោង ឬជាកញ្ចប់

ក្រោមការដឹកនាំរបស់ **លោកឧកញ៉ា លី ហួរ** ប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានធ្វើការដឹកនាំសមាជិក-សមាជិកា ប្រជុំពិភាក្សាបញ្ហាភាពលំបាកលើការអនុវត្តបង់ពន្ធលើវិស័យសំណង់តាមរបបស្វ័យប្រកាស កិច្ចប្រជុំបានប្រព្រឹតទៅជាច្រើនលើកដូចតទៅ៖

- នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ កិច្ចប្រជុំនៅការិយាល័យសមាគម សមាជិក-សមាជិកាសមាគម បានលើកពីផលពិបាក នឹងបញ្ហាប្រឈមជាច្រើនលើការអនុវត្តបង់ពន្ធលើវិស័យសំណង់តាមរបបស្វ័យប្រកាស ជាលទ្ធផល អង្គប្រជុំបានសម្រេចជាឯកច្ឆន្ទ ដោយរៀបចំសំណើសុំទៅអគ្គនាយកដ្ឋានពន្ធដារ សុំមិនបង់ ពន្ធលើវិស័យសំណង់តាមរបបស្វ័យប្រកាស ដោយសុំពន្ធជាគម្រោងវិញ។
- នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦ ក្រោមការដឹកនាំរបស់ លោកឧកញ៉ា លី ហួរ ប្រធានសមាគមដឹកនាំសមាជិក-សមាជិកាប្រជុំពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធដារ អញ្ជើញចូលរួមដោយលោក អេង រតនា ប្រធាននាយកដ្ឋាន អ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ។ ជាលទ្ធផលនៃកិច្ចប្រជុំ សមាគមបានដាក់លិខិតស្នើសុំ លេខៈ០១៣០/០៧១៦ "**ស្តីពីសំណើសុំបង់ពន្ធតាមគម្រោងនៃសំណង់នីមួយៗ**" ហើយ អគ្គ

នាយពន្ធដារ បានទទួលយកសំណើ ដើម្បីដាក់ជូនឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យ និងសម្រេច។

- នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ លោកឧកញ៉ា លី ហួរ ប្រធានសមាគម បានធ្វើលិខិតស្នើសុំជាលើកទី២ លិខិតលេខៈ០១៩៩/១០១៦ "**ស្តីពីការសុំមិនបង់ពន្ធលើវិស័យសំណង់តាមរបបស្វ័យប្រកាស ដោយសុំបង់ពន្ធទៅតាមគម្រោងនីមួយៗវិញ**" ទៅឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ជាលទ្ធផល អគ្គនាយកដ្ឋាន ពន្ធដារ ព្រមព្រៀងទទួលសំណើ និងបានអនុញ្ញាតអោយក្រុមហ៊ុនអ្នកអភិវឌ្ឍន៍អចលនវត្ថុ ទាំងអស់បង់ពន្ធទៅតាមគម្រោងនីមួយៗចាប់ពីឆ្នាំ២០១៧ នេះទៅ រហូតមានការជូនដំណឹងជាថ្មីពី អគ្គនាយកដ្ឋានពន្ធដារ។




រូបភាព៖ សកម្មភាពកិច្ចប្រជុំ

## ៤.កិច្ចប្រជុំនានារបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

❖ **ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ កិច្ចប្រជុំ "សន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០១៦ និងលើកទិសដៅសម្រាប់ឆ្នាំ២០១៧"** នៅសណ្ឋាគារកាំបូឌីយ៉ាណា ពិភាក្សាអំពី៖

- ការបង្ហាញរបាយការណ៍លទ្ធផល និង សកម្មភាពការងារប្រចាំឆ្នាំ២០១៦
- ការរៀបចំផែនការ និង យុទ្ធសាស្រ្តសម្រាប់ឆ្នាំ២០១៧ ដែលមានដូចខាងក្រោម៖

1. ផែនការផ្សព្វផ្សាយពីសមាគមឲ្យគ្រប់មជ្ឈដ្ឋាន ឲ្យទទួលស្គាល់សមាគមកាន់តែច្រើន ពិសេសអ្នកវិនិយោគលើវិស័យអភិវឌ្ឍន៍លំនៅឋាន។
2. ទាក់ទាញអ្នកវិនិយោគវិស័យអភិវឌ្ឍន៍លំនៅឋាន ឲ្យចូលជាសមាជិកសមាគមឲ្យបាន ៤៥ក្រុមហ៊ុន។
3. មានផែនការរកដំណោះស្រាយ និងសំណើសុំបង់ពន្ធលើវិស័យសំណង់ជាគម្រោង ឬជាកញ្ចប់ ទៅអគ្គនាយកដ្ឋានពន្ធដារ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
4. បង្កើតវេទិកាធុរកិច្ចសម្រាប់ពង្រឹង និងពង្រីកទំនាក់ទំនងជាមួយស្ថាប័នដែលពាក់ព័ន្ធ។
5. រៀបចំសម្ភោធអណ្តូងទឹក ចំនួន៥ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់។
6. ផែនការចូលរួមជួយសង្គម។
7. ផែនការធ្វើសន្និបាតវិសាមញ្ញសម្រាប់សមាគម។

៨. ផែនការដឹកនាំសមាជិក-សមាជិកាជួបសំណេះសំណាល និងសម្តែងការគួរសមជាមួយ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ។

៩. ផែនការប្រជុំមហាសន្និបាត និងពិធីជប់លៀង (អញ្ជើញអាជ្ញាធរមានសមត្ថកិច្ចចូលរួម ពិភាក្សាអំពីវិស័យអភិវឌ្ឍន៍លំនៅឋាន)



រូបភាព៖ សមាជិក-សមាជិកាសមាគម និងមន្ត្រីរាជរដ្ឋាភិបាល



រូបភាព៖ ពិធីពិសាអាហារពេលល្ងាច



រូបភាព៖ លោកឧកញ៉ា លី ហួរ ប្រគល់វត្ថុអនុស្សាវរីយជូនមន្ត្រីរាជរដ្ឋាភិបាល

❖ **ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ កិច្ចប្រជុំ "ការផ្សព្វផ្សាយបទពិសោធន៍ការធ្វើកោសលវិច័យអគារសំណង់នៅប្រទេសម៉ាឡេស៊ី និង ប្រទេសជប៉ុន"** នៅសណ្ឋាគារ Raffle Le Royal ពិភាក្សាអំពី៖

➢ការព័ណ៌នាអំពីវិស័យសំណង់

➢បទបង្ហាញស្តីពីការត្រួតពិនិត្យគុណភាពសំណង់អគារនៅប្រទេសម៉ាឡេស៊ី

➢បទបង្ហាញស្តីពីការធ្វើកោសលវិច័យសំណង់អគារនៅប្រទេសជប៉ុន

❖ **ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ កិច្ចប្រជុំ "ការពិភាក្សាជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"** នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភាក្សាអំពី៖

- ការបង្កើតទម្រង់របាយការណ៍ប្រតិបត្តិការសាច់ប្រាក់
- ការទប់ស្កាត់ប្រតិបត្តិការសង្ស័យលើវិស័យអចលនទ្រព្យតាមប្រព័ន្ធទៅអង្គភាពស៊ើបការហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជា ដើម្បីទប់ស្កាត់ការលាងលុយក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា។

 

រូបភាព៖ សកម្មភាពកិច្ចប្រជុំ

- **ថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១៧ "ពិធីពិសារអាហារសាមគ្គី សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា"** នៅសណ្ឋាគារ សុខាភ្នំពេញ ស្តីអំពី៖
  - ការរិតចំណងសាមគ្គីភាពរវាងវិស័យឯកជន និងរាជរដ្ឋាភិបាល
  - ការរិតចំណងសាមគ្គីភាពរបស់សមាជិក-សមាជិកាសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា



រូបភាព៖ រូបថតអនុស្សាវរីយថ្នាក់ដឹកនាំ និងសមាជិក-សមាជិកាសមាគម ជាមួយ
**ឯកឧត្តម ហ៊ុន ម៉ានី**

- **ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧ "ពិធីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់របស់រាជរដ្ឋាភិបាលជាមួយវិស័យឯកជន"** នៅមជ្ឈមណ្ឌលសន្និបាតកោះពេជ្រ ស្ដីអំពី៖
  - ផ្សព្វផ្សាយ និង យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់



រូបភាព៖ ការបើកអង្គពិធីក្រោមអធិបតីភាព **សម្ដេចក្រឡាហោម ស ខេង**


រូបភាព៖**លោកហ៊ុយ វណ្ណា** និង**លោកអ៊ូច ពិសាល**ចូលរួមក្នុងពិធីយុទ្ធនាការ

- **ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ "កិច្ចប្រជុំជាមួយតំណាងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"** នៅការិយាល័យសមាគម ស្ដីអំពី៖
  - ពិភាក្សាលើបញ្ហាច្បាប់អចលនវត្ថុនៅកម្ពុជា


រូបភាព៖ រូបថតអនុស្សាវរីយ លោកឧកញ៉ា លី ហួរ ជាមួយក្រុមការងារខាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


រូបភាព៖ សកម្មភាពអង្គប្រជុំ

- **ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៧ "សន្និបាត និង ពិព័រណ៍អចលនវត្ថុកម្ពុជាឆ្នាំ២០១៧"** នៅសណ្ឋាគារសូហ្វី តែលភ្នំពេញ៖ លោកឧកញ៉ា លី ហួរ ប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ចូលរួមជាគណអធិបតីក្នុង **"ពិធីប្រកាសបើក កម្មវិធីសន្និបាត និងពិព័ណ៌អចលនទ្រព្យកម្ពុជាឆ្នាំ២០១៧"** ក្នុងការបង្ហាញពីភាពរីក ចំរើនលើវិស័យអចលនទ្រព្យ និងដើម្បីផ្សព្វផ្សាយពីវិសាលភាព នៃវិស័យអនលនទ្រព្យនៅកម្ពុជា ទៅអ្នកវិនិយោគក្នុងប្រទេស និងក្រៅប្រទេស ដោយបង្ហាញពី៖
  - ការបង្ហាញពីបទពិសោធន៍ និងភាពជោគជ័យក្នុងការវិនិយោគលើវិស័យអចលនទ្រព្យនៅកម្ពុជា

៦ការបង្ហាញពីភាពរីកចម្រើនលើវិស័យអចលនទ្រព្យ និងផ្សព្វផ្សាយពីវិសាលភាពវិស័យអចលនទ្រព្យនៅកម្ពុជា ទៅអ្នកវិនិយោគក្នុងប្រទេស និងក្រៅប្រទេស។



រូបភាពៈ លោកឧកញ៉ា លី ហួរ ជាមួយភាគីពាក់ព័ន្ធក្នុងវិស័យអចលនទ្រព្យ



រូបភាពៈ អ្នកចូលរួមក្នុងពិធីសន្និបាត

❖ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ “**ការតាំងពិព័រណ៍ វិស័យសំណង់ និងសម្ភារៈសាងសង់ ខ្នាតអន្តរជាតិលំដាប់លេខមួយនៅកម្ពុជា**” នៅមជ្ឈមណ្ឌលសន្និបាតកោះពេជ្រ

នៅព្រឹកថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧នេះ លោក ហ៊ុយ វណ្ណា និងលោក អ៊ូច ពិសាល តំណាងឱ្យសមាគមអ្នកអភិវឌ្ឍលំនៅឋានកម្ពុជា បានចូលរួមជាភ្ញៀវកិត្តិយសក្នុងការតាំងពិព័រណ៍ វិស័យសំណង់ និងសម្ភារៈសាងសង់ ខ្នាតអន្តរជាតិលំដាប់លេខមួយនៅកម្ពុជា។







❖ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ “**សិក្ខាសាលាលើកទី១ ស្តីពី ទិដ្ឋភាពច្បាប់ និងបទដ្ឋានគតិយុត្តិលើការវិនិយោគវិស័យសំណង់នៅកម្ពុជា**” នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ស្តីអំពីៈ

ការរៀបចំសិក្ខាសាលានេះ សមាគមបានសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានពន្ធដារ និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្នុងការធ្វើបទបង្ហាញពីនីតិវិធីស្នើសុំអាជ្ញាបណ្ណអភិវឌ្ឍលំនៅឋាន, នីតិវិធីបង់ពន្ធ និងនីតិវិធីស្នើសុំតភ្ជាប់បណ្តាញទឹកចូលគម្រោងអភិវឌ្ឍផ្សេងៗ។







❖ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ **"ទស្សនកិច្ចពិព័រណ៌ ភ្លើងបំភ្លឺ សំណង់អគារ និង ប្រព័ន្ធសុវត្ថិភាពអគារ"** នៅ **ប្រទេសថៃ៖**

លោកឧកញ៉ា លី ហួរ ប្រធានសមាមគអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានដឹកនាំប្រតិភូសមាគម អ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា អញ្ជើញទៅចូលរួមក្នុងពិធីតាំងពិព័រណ៌ "ស្មាតស៊ីធី សេហ្វស៊ីធី Smart City Safe City" ដើម្បីសិក្សាស្វែងយល់ និងទទួលនូវចំណេះដឹង បទពិសោធន៍ អំពីផលិតផលសម្ភារៈសាងសង់ និងគម្រោងសាងសង់លំនៅឋាននៃប្រទេសថៃ។









**១.ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧**

លោកឧកញ៉ា លី ហួរ ប្រធានសមាគម អនុប្រធាន សមាជិក-សមជិកា និងក្រុមការងារទាំងអស់ បានអញ្ជើញទៅដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ រៀបចំចេញដំណើរទៅកាន់ប្រទេសថៃ ក្នុងគោលបំណងចូលរួមទស្សនកិច្ចពិព័រណ៌ ស្តីពី "SMART CITY, SATE CITY" ដោយបានទៅដល់សណ្ឋាគារ Shangri-La (5 star) ទីក្រុងបាងកក ប្រទេសថៃ វេលាម៉ោង ១:០០ ថ្ងៃត្រង់ ដោយសុវត្ថិភាព។

**២.ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧**

លោកឧកញ៉ា លី ហួរ ប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានដឹកនាំសមាជិក-សមាជិកា និងបុគ្គលិក ចូលរួមសិក្ខាសាលាក្នុងកម្មវិធីតាំងពិព័រណ៌ ស្តីពីបញ្ហាប្រឈមសន្តិសុខ និងសុវត្ថិភាពនៅអគារសាធារណៈ ដោយសហការជាមួយ Mr. Atip Bijanonda, ប្រធានសមាគមអាជីវកម្មលំនៅឋានថៃ (HBA) ដែលប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលពាណិជ្ជកម្ម និងពិព័រណ៌បាងកកៈ

- ✓ លើកិច្ចពិភាក្សាលើសន្តិសុខ និងសុវត្ថិភាពអគារសាធារណៈ
- ✓ សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានពិធីអាហាសាមគ្គីថ្ងៃត្រង់ ជាមួយសមាគមអាជីវកម្មលំនៅឋានថៃ និងពាណិជ្ជករធំៗជាច្រើនទៀត។
- ✓ ទស្សនា ការតាំងពិព័រណ៌ឧបករណ៍ភ្លើងបំភ្លឺ អគារ និងប្រព័ន្ធសុវត្ថិភាពអគារ ។




រូបភាព៖ សិក្ខាសាលា ពិព័រណ៌ឧបករណ៍ភ្លើងបំភ្លឺ អគារ និងប្រព័ន្ធសុវត្ថិភាពអគារ










រូបភាព៖ សិក្ខាសាលា ពិព័រណ៌ឧបករណ៍ភ្លើងបំភ្លឺ អគារ និងប្រព័ន្ធសុវត្ថិភាពអគារ







រូបភាព៖ សកម្មភាពទស្សនា ការតាំងពិព័រណ៌ឧបករណ៍ភ្លើងបំភ្លឺ អគារ និង
ប្រព័ន្ធសុវត្ថិភាពអគារ






រូបភាព៖ សកម្មភាពទស្សនា ការតាំងពិព័រណ៍ឧបករណ៍ភ្លើងបំភ្លឺ  អគារ និង
ប្រព័ន្ធសុវត្ថិភាពអគារ















រូបភាព៖ សកម្មភាពទស្សនា ការតាំងពិព័រណ៌ឧបករណ៍ភ្លើងបំភ្លឺ អគារ និង
ប្រព័ន្ធសុវត្ថិភាពអគារ

### ៣.ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៧

- ✓ ដំណើរទស្សនកិច្ច គម្រោងបុរីចំនួនពីរ ១)បុរីលំនៅឋានប្រណិត CRYSTAL PARK & GRAND ២)គម្រោងលំនៅឋានតម្លៃមធ្យម SUPALAI PRIDE។
- ✓ នៅវេលាម៉ោង១០:០០នាទីព្រឹក កិច្ចស្វាគមន៍របស់ក្រុមហ៊ុន K.E Group នៅមជ្ឈមណ្ឌលរចនាត្រីស្តាល់ Crystal Design Center (CDC) បានធ្វើបទបង្ហាញ និង មគ្គុទេសក៍សមាជិក-សមាជិកាទៅកាន់បន្ទប់តាំងបង្ហាញអំពីផលិតផល និង សម្ភារៈសាងសង់លំនៅឋានប្រណិត។
- ✓ CRYSTAL PARK & GRAND ដែលរៀបចំដោយក្រុមហ៊ុន K.E. Group ជាម្ចាស់គម្រោងនេះ និងជាអនុប្រធានសមាគមអាជីវកម្មលំនៅឋានថៃបានធ្វើបទបង្ហាញពីភាពជោគជ័យ និងផ្តល់បទពិសោធន៍ក្នុងការគ្រប់គ្រង និងការលក់លំនៅឋានក្នុងប្រទេសថៃ។
- ✓ ដំណើទស្សនកិច្ច គម្រោងលំនៅឋានតម្លៃមធ្យម SUPALAI PRIDE ក្រោមកិច្ចសហការប្រកបដោយក្តីរីករាយ យើងបានបន្តដំណើរទៅកាន់ ដំណើទៅទស្សនកិច្ចគម្រោងលំនៅឋានតម្លៃមធ្យម SUPALAI PRIDE ដែលស្ថិតនៅតាមបណ្តោយផ្លូវទៅកាន់អាកាសយានដ្ឋានអន្តរជាតិសុវណ្ណាភូមិ ប្រទេសថៃ។
- ✓ យើងបានទទួលនូវបទពិសោធន៍ និង កាចែករំលែកចំណេះដឹងថ្មីៗ ការរចនាម៉ូដផ្ទះ ការរៀបចំហេដ្ឋារចនាសម្ពន្ធ ការគ្រប់គ្រង ការលក់ ។ល។






រូបភាព៖ សកម្មភាពទស្សនកិច្ច គម្រោងលំនៅឋាន

❖ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៧ "**សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានទទួលពានរង្វាន់គុណភាព អន្តរជាតិ BID**" នៅទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស។

**លោកឧកញ៉ា លី ហួរ ប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានផ្ដល់បទសម្ភាស នៅទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស** ដោយបានលើកឡើងពីកត្តាជោគជ័យរបស់សមាគម ក្នុងការទទួលបានពានរង្វាន់គុណភាពអន្តរជាតិ BID នៅទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស មានដូចជា៖

៚សមាជិករបស់សមាគមទាំងអស់សុទ្ធតែជាក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋាប ដែលមានកេរ្តិ៍ឈ្មោះល្អ និងបានរួមចំណែកក្នុងការចែករំលែកផ្ដល់បទពិសោធន៍រវាងគ្នាទៅវិញទៅមក។

៚សមាគមមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់។

៚ការអភិវឌ្ឍន៍លំនៅឋានរបស់សមាគម គឺផ្ដោតជាចម្បងទៅលើផ្នែកគុណភាពសំណង់ តាមរយៈការសាងសង់ប្រកបដោយបច្ចេកទេស។

៚ការសាងសង់លំនៅឋានប្រកបដោយសោភ័ណភាព ត្រូវបានសមាគមសម្រិតសម្រាំង និងរចនាប្រកបដោយភាពស្រស់ស្អាតទាក់ទាញ។

៚សមាគមតែងសាងសង់នូវលំនៅឋាន ដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។







រូបភាព៖ កិច្ចសម្ភាសជាមួយឧកញ៉ា លី ហួរ មុនពេលទទួលពាន់រង្វាន់អន្តរជាតិ BID










រូបភាព៖ ក្រុមអគ្គលេខាដ្ឋាន ធ្វើបទបង្ហាញពីសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

ពេលទទួលពានរង្វាន់អន្តរជាតិ BID




រូបភាព៖ សកម្មភាពក្នុងពេលទទួលពានរង្វាន់អន្តរជាតិ BID




រូបភាព៖ សកម្មភាពក្នុងពេលទទួលពានរង្វាន់អន្តរជាតិ BID

❖ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧ "**វេទិកាធុរកិច្ចកម្ពុជា-សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី** " នៅសណ្ឋាគារសុខាភ្នំពេញ

លោកឧកញ៉ា លី ហួរ ប្រធានសមាគមអ្នកអភិវឌ្ឍន៍នៅឋានកម្ពុជា និងជាអនុប្រធានសភាពាណិជ្ជកម្មកម្ពុជា បានចូលរួមជាកិត្តិយស និងបានថ្លែងសន្ទរកថា បង្ហាញពីការអភិវឌ្ឍន៍ និងឱកាសក្នុងការវិនិយោគលើវិស័យអចលនទ្រព្យកម្ពុជា ក្នុងវេទិកាធុរកិច្ចកម្ពុជា-សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម និងសភាពាណិជ្ជកម្មកម្ពុជា។










រូបភាព៖ សកម្មភាពក្នុងវេទិកាធុរកិច្ច ក្រោមអធិបតី ឯកឧត្តម ប៉ាន់ សូរស័ក្តិ
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ៥.របាយការណ៍អភិវឌ្ឍន៍វិស័យសំណង់

| កាលបរិច្ឆេទ | គម្រោងសាងសង់ | ផ្ទៃក្រឡាសំណង់សរុប (លានម៉ែត្រការ៉េ) | ទឹកប្រាក់វិនិយោគ (លានដុល្លារអាមេរិក) | អត្រាបម្រែបម្រួល (ភាគរយ) |
|---|---|---|---|---|
| ត្រីមាសទី១ ឆ្នាំ២០១៦ | 473 | 3.79 | 1,647 | |
| ត្រីមាសទី១ ឆ្នាំ២០១៧ | 786 | 2.07 | 1,282 | - 22.16 |
| ត្រីមាសទី២ ឆ្នាំ២០១៦ | 1,183 | 10.51 | 3,879 | |
| ត្រីមាសទី២ ឆ្នាំ២០១៧ | 1,523 | 7.28 | 4,943 | + 27.44 |

**ចំណាំ៖** នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៧ វិស័យសំណង់ នៅកម្ពុជា មានទុនវិនិយោគសរុបជាង ១.២ពាន់លានដុល្លារអាមេរិក ធ្លាក់ចុះជាង ២២ភាគរយ បើធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន។ ប៉ុន្តែបើយើងពិនិត្យមើលសំណង់លំនៅឋាន និងបុរី គិតត្រឹមខែមិនា ឆ្នាំ២០១៧ ការវិនិយោគមាន ៦៧០គម្រោង ស្មើទឹកប្រាក់ ៩៣៩ លានដុល្លារអាមេរិក មានការកើនឡើង ៣៣.១៨ភាគរយ បើធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន។

នៅក្នុងត្រីមាសទី២ ឆ្នាំ២០១៧ វិស័យសំណង់នៅកម្ពុជាមានទុនវិនិយោគសរុបជិត ៥ពាន់លានដុល្លារអាមេរិក កើនឡើងជាង ២៧ភាគរយ បើធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន។

## ៨.ផែនការអនុវត្តបន្ត

1. ពង្រីកកិត្តិនាម និងកិត្យានុភាពរបស់សមាគមឱ្យកាន់តែល្បីសុសសាយ ដល់អ្នកវិនិយោគសំណង់ក្នុងស្រុក និងលើឆាកអន្តរជាតិផងដែរ។
2. ទាក់ទាញក្រុមហ៊ុនវិនិយោគសំណង់លំនៅឋានថ្មីៗ ដែលសក្តានុពលខ្លាំងចូលជាសមាជិកសមាគមឲ្យបានជាអតិបរិមា ជាពិសេសជម្រុញឱ្យអ្នកវិនិយោគបរទេសឱ្យមកប្រទេសកម្ពុជាកាន់តែច្រើន។
3. បង្កើតវេទិកាធុរកិច្ចក្នុងស្រុកសម្រាប់ពង្រឹង និងពង្រីកទំនាក់ទំនងជាមួយស្ថាប័នដែលពាក់ព័ន្ធ ឱ្យកាន់តែជិតស្និទ្ធ ជាពិសេសសហប្រតិបត្តិការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរមូលដ្ឋាន អគ្គនាយកដ្ឋានពន្ធដារ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញជាដើម។
4. បង្កើតដំណើរទស្សនកិច្ចជូនសមាជិក-សមាជិកា ដើម្បីចែករំលែកបទពិសោធន៍ និងសិក្សាស្វែងយល់ពីបច្ចេកទេសគ្រប់គ្រងសំណង់ថ្មីៗ នៅក្នុងតំបន់ និងលើពិភពលោក។
5. ផែនការពង្រឹកផ្ទៃក្នុងរបស់សមាគមឱ្យកាន់តែរឹងមាំ តាមរយៈការរៀបចំសន្និបាតវិសាមញ្ញជួបជុំសមាជិក-សមាជិកាទាំងអស់ ។
6. ផែនការដឹកនាំសមាជិក-សមាជិកាជួបសំណេះសំណាល និងសម្តែងការគួរសមជាមួយ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ។

**រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨**
**រៀបចំដោយ**
**អគ្គលេខាធិការ**

**ហ៊ុយ វណ្ណា**

**រាជធានីភ្នំពេញ ថ្ងៃទី22 ខែ02 ឆ្នាំ២០១៨**
**បានឃើញ និងឯកភាព**
**ប្រធានសមាគម**

**ឧកញ៉ា លី ហួរ**